ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ
រឿងក្ដីព្រហ្មទណ្ឌ
លេខ:៥២៤៧
ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦
សំណុំរឿងជំនុំជម្រះ
លេខ:២១២
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧
សាលក្រមព្រហ្មទណ្ឌ
លេខ៩៦ ក្រ៣(ធ)
ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ដោយមានសមាសភាព៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

-លោក .... អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

-លោក .... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-លោក .... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក .... ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក ......ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើបណ្ដឹងរឿងព្រហ្មទណ្ឌលេខ៥២៤៧ចុះថ្ងៃទី៣១-១០-២០១៦ ដែលមានជនជាប់ចោទ៖

-ឈ្មោះ.....ភេទប្រុសអាយុ៣៨ឆ្នាំជាតិខ្មែរ មុខរបរជាងធ្វើពិដាន ទីកន្លែងកំណើត ភូមិអូរអង្រែ ឃុំអូរអង្រែ ស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ ទីលំនៅបច្ចុប្បន្ន មិនពិតប្រាកដ ឪពុកឈ្មោះ....ម្ដាយឈ្មោះ...ប្រពន្ធឈ្មោះ...(លែងលះ) មានកូន០២នាក់ ទោសពីមុនគ្មាន។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៦៦៧៧(ធ) ដ,ឃ,ដ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ(ម១)

មានលោក.......ជាមេធាវីការពារសិទ្ធិជនជាប់ចោទ(ចាត់តាំង)។

ជាប់ចោទពីបទៈឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់ លេខ២០សេ ជាន់ទី៣ ផ្ទះសំណាក់ឃីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចកខណ្ឌដូនពេញរាជធានីភ្នំពេញកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦។

បទល្មើសដែលមានចែងនិងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌនិងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្ដឹងឈ្មោះ........មានទីលំនៅផ្ទះជួល ផ្លូវ២៧១ ក្រុម២ ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជនីភ្នំពេញ។

## អង្គហេតុនៃរឿងដូចតទៅៈ

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៦ និង៣០នាទី បន្ទាប់ពីខឹងជនរងគ្រោះឈ្មោះ.....អាយុ២២ឆ្នាំ ដែលជាសង្សារថាមានប្រុសច្រើន រួចមកជនសង្ស័យឈ្មោះ......បានទៅជួលបន្ទប់លេខ២០សេ ជាន់ទី៣ ផ្ទះសំណាក់ឃីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់

ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងបានណាត់ជនរងគ្រោះ ឱ្យមកដេក ជាមួយ ហើយនៅយប់ថ្ងៃដដែលនោះជនរងគ្រោះក៏បានមកដេកជាមួយជន សង្ស័យ និងបានរួមរ័កគ្នា ចំនួន០៣ លើក។ បន្ទាប់ពីរួមរ័កគ្នារួចមកជន សង្ស័យបានឈ្លោះប្រកែកគ្នាជាមួយជនរងគ្រោះ ហើយជនសង្ស័យក៏បាន ធ្វើ សកម្មភាពសម្លាប់ជនរងគ្រោះតែម្តង ។ក្រោយពេលសម្លាប់ជនរងគ្រោះរួចជន សង្ស័យឈ្មោះ...បានដោះយកខ្សែកប្លាកទីន០១ខ្សែ កងដៃប្លាកទីនចំនួន០៣ កង និងទូរស័ព្ទដៃម៉ាក iPhone ស៊ិចភ្លើស ចំនួន០១គ្រឿង របស់ជនរងគ្រោះ រួចគេចខ្លួនបាត់។លុះដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ ជនសង្ស័យត្រូវបាន សមត្ថកិច្ចឃាត់ខ្លួន។ ក្រោយពេលឃាត់ខ្លួនសមត្ថកិច្ច បានយកទឹកនោមជន សង្ស័យទៅធ្វើតេស្ត រកសារធាតុញៀនជាលទ្ធផលបង្ហាញថាមានសារធាតុញៀន ប្រភេទមេតំហ្វេតាមីន។

បានឃើញរបាយការណ៍សំយោគលេខ ១២៣/១៦ របក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៣០៧១ អយត ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជ ធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៣៥៨៣ អយត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាដំណោះស្រាយលេខ៤៥៨៨ (ធ) ជជ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## ទាពេលសវនាការ

-ជនជាប់ចោទឈ្មោះ......បានឆ្លើយថា៖កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៦ ខ្លួនបានទូរស័ព្ទណាត់ជាមួយឈ្មោះ..ភេទស្រីអាយុ២២ ឆ្នាំទៅជួបគ្នានៅម៉ោង៤ឬ៥ល្ងាចនៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុនខ្លួន ក៏បានជួលបន្ទប់ផ្ទះសំណាក់លេខ២០សេ ដល់ម៉ោង៥និង៣០នាទីឈ្មោះ.......បានមកដល់បន្ទាប់មកពួកខ្ញុំបានរួមភេទជាមួយគ្នា ក្រោយពីរួមភេទរួច ម៉ោងប្រហែល៩និង៣០នាទី ពួកខ្លួនបាននិយាយគ្នា ដោយខ្លួនថាឱ្យគាត់ឈប់ធ្វើការជានារី ខារ៉ាអូខេ តែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបង្អួតខ្លួនថា គាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរស័ព្ទឆ្លើយឆ្លងនៅចំពោះមុខខ្លួន ដោយពេលនោះខ្លួនខឹងពេកក៏បានសង្គ្រប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតប្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួច ខ្លួនបានដោះខ្សែក ដោះខ្សែដៃ និងទូរស័ព្ទរបស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង បន្ទាប់មកដើរចេញពីផ្ទះសំណាក់ ហើយហៅម៉ូតូឌុបជិះចេញទៅបាត់ តែម្តង (នៅពេលខ្លួនដើរចេញពីផ្ទះសំណាក់មិនបានពាក់ម៉ាសទេ) នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១១ថ្ងៃត្រង់ ក៏មានសមត្ថកិច្ចធ្វើការឃាត់ខ្លួនសាកសួរ ហើយខ្លួនក៏ឆ្លើយសារភាពតាមសកម្មភាពដែលខ្ញុំបានប្រព្រឹត្តតែម្តង។ មូលហេតុ ដែលខ្លួនសម្លាប់ហើយយកខ្សែក និងកងដៃរបស់ជនរងគ្រោះព្រោះវាជារបស់ដែលខ្លួនបានធ្វើឱ្យនាង ចំណែកឯទូរស័ព្ទគឺ ជារបស់គាត់។ ខ្លួនមិនមែនណាត់ជួបគាត់ ដើម្បីប្លន់យកទ្រព្យសម្បត្តិរបស់គាត់នោះទេ។ ខ្លួននិងជនរងគ្រោះស្គាល់គ្នា និង ទាក់ទងគ្នាជាសង្សារប្រហែល១ឆ្នាំ ហើយពួកខ្លួនធ្លាប់

ណាត់ជួបគ្នាជារឿយៗ ទើបតែលើកចុងក្រោយនេះ គាត់ទើបធ្វើឱ្យខ្លួន ដឹងថា គាត់មានសង្សារច្រើន ថែមទាំងទូរស័ព្ទនិយាយជាមួយប្រុសផ្សេង នៅមុខខ្លួនទៀត ខ្លួនខឹងពេកដោយទ្រាំនឹងគាត់បញ្ឈឺមិនបាន ក៏សម្លាប់គាត់តែម្តង។ នៅមុនពេលសម្លាប់ជនរងគ្រោះ ខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ តែមុនពេលឃាត់ខ្លួន ខ្លួនបានប្រើប្រាស់ថ្នាំញៀនពិតមែន។ ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចទៅតាមច្បាប់ ដោយខ្លួនដឹងអំពីកំហុសរបស់ខ្លួន ហើយស្តាយចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តលើជនរងគ្រោះ។

-តាមអំណានចម្លើយដើមបណ្តឹងឈ្មោះ........បានឆ្លើយថា៖កាលពីថ្ងៃទី២៤ ខែតុលាឆ្នាំ២០១៦ ម៉ោងប្រហែល ១៦និង៣០នាទី ប្អូនស្រីខ្លួនឈ្មោះ.....ភេទស្រីអាយុ២២ ឆ្នាំមុខរបរបុគ្គលិកខារ៉ាអូខេ ហេងហេង(DN)ស្នាក់នៅផ្ទះជួល លេខ១៦សេ-១៦ដេ ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានស្រុកកំណើតនៅ ភូមិស្នាយពល ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង (ត្រូវជាប្អូនបង្កើតរបស់ខ្លួន) បានចេញពីផ្ទះដោយប្រាប់អ្នកនៅជាមួយថាទៅកក់សក់រួច ក៏ចេញបាត់ទៅលុះដល់ថ្ងៃទី២៥ខែតុលាឆ្នាំ២០១៦ ម៉ោងប្រហែល១៨ និង៣០ នាទី ខ្លួនបានទទួលដំណឹងតាមរយៈមិត្តភក្រ្តប្អូនស្រីថា ប្អូនស្រីខ្លួនឈ្មោះ.......ត្រូវបានគេសម្លាប់ ឥឡូវសពតម្កល់នៅវត្តស្ទឹងមានជ័យ។ បានដំណឹងនេះ ខ្លួនក៏ធ្វើដំណើរទៅកាន់វត្តស្ទឹងមានជ័យកន្លែងតម្កល់សពឃើញថាសពនោះពិតជាប្អូនស្រីបង្កើតខ្លួនឈ្មោះ......ពិតប្រាដកមែន។ សម្ភារប្រើប្រាស់ប្រចាំថ្ងៃរបស់ប្អូនស្រីខ្លួនជាប់នឹងខ្លួនមានកងដៃផ្លាកទីនចំនួន០៣កងខ្សែកផ្លាកទីន០១ខ្សែ ទម្ងន់ប្រហែល០២ជី ទូរស័ព្ទដៃម៉ាកiPhone ស៊ិចភ្លើស ០១គ្រឿង ពណ៌ទឹកមាស ប្រើស៊ីមស្មាតលេខ០៨៧ ៦៧៤៧៤៧។

-តាមអំណានចម្លើយសាក្សីឈ្មោះ.......បានឆ្លើយថា៖ ខ្លួនបានស្គាល់ឈ្មោះ.........រយៈពេលមួយឆ្នាំហើយ ពេលធ្វើការជាមួយគាត់ នៅខារ៉ាអូខេហេងហេង(២)ម្តុំក្បែរបុស្តិ៍នគរបាលផ្សារដេប៉ូ៣ ។នៅឆ្នាំ២០១៥ ប្រហែលក្នុងខែ៧ ឆ្នាំ ២០១៦ ខ្លួនក៏ឈប់ធ្វើការនៅហេងហេង(២)ហើយទៅធ្វើការនៅឌីយ៉ាម៉ង់វិញ(ម្តុំអូរបែកក្អម)។ ឈ្មោះ...គាត់មានសង្សារ ម្នាក់ឈ្មោះ.......ភេទប្រុសអាយុប្រហែល២០ ឆ្នាំជាង មានមុខរបរធ្វើអ្វីពុំដឹងទេ លេខទូរស័ព្ទមិនស្គាល់ ខ្លួនជួបគាត់នៅផ្ទះ ជួលរបស់បងឈ្មោ.....ជិតខារ៉ាអូខេហេងហេង (២) នាងជួបឈ្មោះ......ប្រហែល៣ដងជួបម្តងៗមួយភ្លែតៗប៉ុណ្ណោះឈ្មោះ មានកំពស់ប្រហែល១,៧០ម សក់ស្លូតច្រមុះស្រួចសម្បុរខ្មៅស្រអែម។ នៅថ្ងៃទី២៤ខែតុលា ឆ្នាំ២០១៦វេលាម៉ោងប្រហែល ១៩និង០០នាទី ខ្លួនបានទូរស័ព្ទទៅបងឈ្មោះ......លេខ០៨៧ ៦៧៤៧៤៧ ដើម្បីខ្ចីលុយគាត់២០ដុល្លា តែគាត់ថាកំពុងនៅផ្ទះសំណាក់ ចាំគាត់តេមកវិញ ពេលនោះគឺខ្លួនកំពុងនៅខារ៉ាអូខេឌីយ៉ាម៉ង់អូរបែកក្អម ខ្លួនចាំរហូតដល់ម៉ោង១០យប់ ថ្ងៃដដែលក៏ទូរស័ព្ទទៅម្តងទៀតតែពុំចូលរហូតដល់ម៉ោង១១យប់ តេច្រើនលើកនៅតែពុំចូល។ លុះព្រឹកឡើងថ្ងៃទី២៥ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៩ និង០០នាទីឈ្មោះ.....ភេទស្រីនៅខារ៉ាអូខេជាមួយខ្លួនប្រាប់ថាបងឈ្មោះ.....ប្រាប់ហើយត្រូវគេសម្លាប់ លុះព្រឹកឡើងថ្ងៃទី២៦ខែតុលាឆ្នាំ២០១៦ ខ្លួនក៏ទៅធ្វើបុណ្យគាត់ នៅខេត្តព្រៃវែងជាមួយមិត្តភក្តិ៤នាក់ទៀត។

-តាមអំណានចម្លើយសាក្សីឈ្មោះ.....បានឆ្លើយថា៖ខ្លួននិងឈ្មោះ......បានជួលផ្ទះលេខ១៦សេ រស់នៅជាមួយគ្នា ចំនួន០៤នាក់រយៈប្រហែល០៤ខែហើយ ប៉ុន្តែខ្លួនស្គាល់គ្នារយៈពេល៣ឆ្នាំហើយ ។អ្នកនៅជាមួយគ្នានោះ /១-ឈ្មោះ....... ហៅលីហ្សា ទូរស័ព្ទ០៩៦៥៨០១២១ /២-ឈ្មោះ.......ភេទស្រី

អាយុ១៩ឆ្នាំទូរស័ព្ទ០៩៦៥០៨៤៧៤៦ /៣-ឈ្មោះ.......ភេទ ស្រីអាយុប្រហែល ២០ឆ្នាំ ទូរស័ព្ទ០១៦៥០៥៣៣៨ /៤-ឈ្មោះ.......ភេទស្រីអាយុប្រហែស២៨ឆ្នាំ ទូរស័ព្ទមិនស្គាល់ ទើបមកនៅបានប្រហែល១អាទិត្យ ។ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០១៦ ម៉ោងប្រហែល២៣ឬ២៤និង០០នាទី បានមកលេង ក្នុងហាងមួយ សន្ទុះហើយចេញទៅវិញ លុះម៉ោង១និង៣០នាទី ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ពេលខ្លួនចេញពីកន្លែងធ្វើ ការមកផ្ទះ ស្រាប់តែឃើញឈ្មោះ......នៅក្នុងផ្ទះ ជាមួយឈ្មោះ.......ក្មួយប្រុសម្នាក់អាយុ៧ឆ្នាំនិងសង្សារ(សព)ឈ្មោះ.......ហើយ ខ្លួនក៏ចូលដេកនិងនៅជាមួយគ្នារហូតដល់ម៉ោង១៥ និង៩០នាទី ថ្ងៃខែដដែល ទើបខ្លួនចេញទៅកន្លែងធ្វើសក់មុនគេ ពេលដែលខ្លួនកំពុងនៅក្នុងបន្ទប់ជាមួយ ឈ្មោះ.....ពីម៉ោង១២ដល់ម៉ោង១៥ ថ្ងៃទី២៤ ខែតុលាឆ្នាំ២០១៦ ....មាន មនុស្ស ប្រុសតែមកប្រហែល២-៣ដង លើកទី១ ណាត់ឱ្យ.....ជួបគ្នាញ៉ាំអីនៅ វត្តដំបូកខ្ពស់ តែខ្លួនប្រាប់ឈ្មោះ.....ថាកុំទៅអីឆ្ងាយណាស់ លើកទី២ តេមកតែ ឈ្មោះ......អត់លើកទូរស័ព្ទលើកទី៣ តេមកម្តងទៀតប្រាប់ថាទៅជួបពួកម៉ាក នៅម្តុំក្តាន់ពីរសិន បន្តិចទៀតចាំជួបគ្នា ដល់ពេលឈ្មោះ......ទៅជួបអ្នកដែល ទូរស័ព្ទមកនោះមិនដឹងម៉ោងប៉ុន្មានទេ ព្រោះខ្លួនចេញទៅកន្លែង កក់សក់បាត់ ហើយ ។អ្នកដែលតេមកទូរស័ព្ទឈ្មោះ.......នោះខ្លួនអត់ស្គាល់លេខទេ ឮតែស ម្លេងនិយាយឆ្លើយឆ្លងគឺមនុស្សប្រុស។ លុះម៉ោង២៤ និង០០នាទី ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០១៦ ដោយបាត់ឈ្មោះ......មិនមកធ្វើការខ្លួនបានទូរស័ព្ទទៅ លេខ ០៨៧៦៧៤៧៤៧ តែតេមិនចូលរហូតដល់ម៉ោង១១ និង៣០នាទីថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០១៦ ក៏តេមិនចូល លុះ ម៉ោង១៦ និង០០នាទី ថ្ងៃខែដដែលខ្លួនបើក ហ្វេសបុកមើល ស្រាប់តែឃើញរូបភាពឈ្មោះ....ស្លាប់ដែលគេបង្ហោះទើបមាន ការភ្ញាក់ផ្អើលប្រាប់មិត្តភក្តិតៗគ្នា។

-តាមអំណាចចម្លើយសាក្សីឈ្មោះ......បានឆ្លើយថា៖ ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់អូយេស លេខ១៧ ផ្លូវ លេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលាឆ្នាំ ២០១៦ វេលា ម៉ោង ១៦និង៤៥នាទី មានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល៣២ ប្រើទូរស័ព្ទលេខ០៩៦ ៨៣៧៦៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ៨ដុល្លា បន្ទប់លេខ២០សេជាន់ទី៣ពេលបង់ប្រាក់រួចភ្ញៀវបានទិញភេសជ្ជៈចំនួន៤ដប (គោជល់១ដប ទឹកសណ្តែក១ដប បាកាស១កំប៉ុង ទឹកហេវ្រនយ៉ា១ដប) ហើយបានឡើងបន្ទប់លេខ២០សេ ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឱ្យឡើងទៅបន្ទប់២០សេ ខ្លួនក៏ប្រាប់ឱ្យឡើងមកជាន់ទី៣ ជាប់នឹងជណ្តើឡើង។ លុះដល់ វេលាម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោះ........ភេទស្រីអាយុ២៤ ជាអ្នកសំអាតបន្ទប់ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់លេខ២០សេ ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេក ដណ្តប់ភួយស្លាប់នៅលើគ្រែ។ ពេលភ្ញៀវប្រុស ចុះចេញពីបន្ទប់លេខ២០សេ នោះមិនដឹងចុះតាំងពីពេលណាទេ។ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល១៦ និង៥០នាទីខ្លួនកំពុងតែប្រចាំការនៅកន្លែងទទួលភ្ញៀវ ក៏មានភ្ញៀវដែលនៅ បន្ទប់លេខ២០សេ ជាន់ទី៣ ក្នុងផ្ទះសំណាក់អូយេស ភេទប្រុស(ជនសង្ស័យ)បានទូរស័ព្ទលើតុហើយខ្លួនបានលើក ហើយប្រាប់ខ្លួនថាទិញកាតទូរស័ព្ទស្មាត ១ដុល្លាៗចំនួន២សន្លឹក ពេលនោះខ្លួនក៏បានវាយអាយកូមទៅឈ្មោះ...ភេទប្រុស អាយុ២០ឆ្នាំ ឱ្យយកកាតទៅឱ្យភ្ញៀវខាងលើ។ ចំពោះកាតទូរស័ព្ទស្មាតវិញ គឺខ្លួនត្រូវបានថៅកែទុកឱ្យលក់៥០ដុល្លា មានប្រភេទស្មាត១ដុល្លាសែលខាតនិងមេតហ្វូនគឺគាត់ទុក

ឱ្យលក់ (ចុចពីម៉ាស៊ីនទុកឱ្យលក់) ហើយលក់អស់ទើបចុចឱ្យខ្ញុំទៀត រីឯលុយគឺគិតតាមកាត ហើយទូទាត់ឱ្យថៅកែ។

-តាមអំណានចម្លើយសាក្សីឈ្មោះ......បានឆ្លើយថា៖ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១១និង៣០ នាទី ខ្លួនបានឡើងមកឆែកបន្ទប់លេខ២០សេ ជាន់ទី៣ ពេលឡើងមកដល់មុខបន្ទប់ឃើញបន្ទប់ជាប់សោ រួចបានគោះបន្ទប់ហៅភ្ញៀវខាងក្នុងចំនួន៣ដង តែមិនឃើញភ្ញៀវឆ្លើយតបក៏បានចុះទៅខាងក្រោមយកកូនសោ មកចាក់បន្ទប់លេខ២០សេ បើកទ្វារខ្លួនក៏សួរថាបងថែមម៉ោងឬអត់ភ្ញៀវដេកដណ្តប់ភួយមិនឆ្លើយ ខ្លួនក៏បានយកដៃទៅអង្រួនជើង ស្រាប់តែឃើញជើងភ្ញៀវត្រជាក់ ពេលនោះនាងខ្ញុំក៏បានហៅអ្នកខាងក្រោមឱ្យជួយពិនិត្យមើល ឃើញភ្ញៀវកំពុងតែដេកស្ពូកមិនកម្រើក រួចប្រាប់ទៅម្ចាស់ផ្ទះហើយរាយការណ៍ទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលស្រះចកតែម្តង។

-តាមអំណានចម្លើយសាក្សីឈ្មោះ....បានឆ្លើយថា៖នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៦ និង៤០នាទី ខ្លួនកំពុងឈរមុខផ្ទះសំណាក់ឃើញមនុស្សម្នាក់ ភេទប្រុសអាយុប្រហែល៣២ឆ្នាំ ស្លៀកពាក់ស៊ីវិល ពាក់អាវសាច់ក្រណាត់ដៃវែងពណ៌ក្រឡាការ៉ូ ខោពណ៌ខ្មៅជើងវែង ដើរចូលមកក្នុងផ្ទះសំណាក់ម្នាក់ឯងមកជួបឈ្មោះ......ភេទប្រុស(អ្នកគ្រប់គ្រង)រកបន្ទប់ដេក រួចមនុស្សប្រុសនោះដើរឡើងមកបន្ទប់ជាន់ទី៣បាត់រហូត ដល់ម៉ោងប្រហែល១៧ និង០០នាទី ខ្លួនឃើញនារីនោះមកពីទិសខាងកើតផ្ទះសំណាក់ហើយឈប់មុខផ្ទះសំណាក់រួចរាប់លុយឱ្យអ្នកឌុបចេញទៅបាត់ ចំណែក នារីនោះក៏ដើរឡើងមកជាន់ទី៣បាត់រហូតដល់ម៉ោង១៩ និង០០នាទី ខ្លួនដល់ម៉ោង ត្រូវឈ្មោះ......ដល់ថ្ងៃទី២៥ តុលា ឆ្នាំ២០១៦ ខ្លួនយាមវិញវេលាម៉ោងប្រហែល១១ និង០០នាទីឈ្មោះ....ភេទស្រី (អ្នកបោសសម្អាតបន្ទប់) បានប្រាប់ខ្លួនថាបន្ទប់លេខ២០

សេ ជាន់ទី៣ ដែលភ្ញៀវចូលដេកនៅថ្ងៃទី២៤ ខែតុលាឆ្នាំ២០១៦(មានស្រីម្នាក់ និងប្រុសម្នាក់)បិទទ្វារហៅ មិនមានការឆ្លើយតបក៏ឱ្យខ្ញុំជួយមើលពេលខ្លួនមើល ជាមួយស្រីនាងឃើញមនុស្សស្រីដេកស្លកលើពូក ខ្លួនក៏ទៅប្រាប់ម្ចាស់ ផ្ទះតែម្តង ។តាមកាចំណាំរបស់ខ្លួនកន្លងមកខ្លួនមិនដែលឃើញបុរសនោះ និងនារីរងគ្រោះចេញចូលផ្ទះសំណាក់នេះទេ (ជាម៉ូយថ្មី)។នៅថ្ងៃទី២៤ ខែតុលាឆ្នាំ២០១៦ ម៉ោងប្រហែល១៦ជាងជិតម៉ោង១៧ ពេលមនុស្សប្រុសនោះ ទិញកាតបញ្ចូលទឹកប្រាក់ចំនួន១ដុល្លា ចំនួនពីរសន្លឹកពីឈ្មោះ........ប៉ុន្តែខ្លួនមិនដឹងថាមនុស្សប្រុសនោះចេញពីផ្ទះសំណាក់ពេ ណានោះទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ.....បានឆ្លើយថា៖ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ខ្ញុំកំពុងប្រកបអាជីវកម្មទិញ -លក់គ្រឿងអលង្ការ យីហោ ចាបមាស តូបលេខ៥០អា ផ្សារសាមគ្គី ស្ថិតនៅក្នុងសង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ម៉ោងប្រហែល៩ និង០០នាទីព្រឹក មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះបានយកគ្រឿងអលង្ការផ្លាកទីនមាន កងដៃចំនួន៣កង និងខ្សែកមួយខ្សែយកមកលក់ ពេលនោះខ្លួនសួរថារបស់ទាំងហ្នឹងទិញពីកន្លែងណាមកជននោះក៏យក វិក័យបត្រដែលមានយីហោតូបរបស់ខ្លួនមកបង្ហាញដោយឃើញវិក័យបត្រនេះខ្ញុំក៏យល់ព្រមទិញហើយបានយកថ្លឹងដោយ កងដៃ៣កងទម្ងន់មួនជីមួយហ៊ុន ចំណែកខ្សែកមានទម្ងន់មួយជីបួនហ៊ុនបីលី សរុបទាំងអស់ខ្ញុំទិញក្នុងតម្លៃទីផ្សារសរុប៣៦៩ដុល្លា ។លុះដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦ ម៉ោង៩និង០០នាទីព្រឹក ក្រោយពីខ្លួនដឹងថារបស់ខាងលើពាក់ពន្ធ័ ជាវត្ថុតាងនៅអំពើល្មើសច្បាប់ ខ្លួនបានសហការណ៍ប្រគល់ឱ្យសមត្ថកិច្ច ដើម្បីទុកជាវត្ថុតាង។

-តាមអំណានចម្លើយសាក្សីឈ្មោះ.....បានឆ្លើយថា៖ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១១ថ្ងៃត្រង់ ខ្លួនកំពុងនៅហាងលក់ទូរស័ព្ទរបស់ឈ្មោះ......ពេលនោះក៏មានមនុស្សចំនួន២នាក់ ជិះម៉ូតូម៉ាកហុងដា១២៥ មិនដឹងស៊េរី បានយកទូរស័ព្ទម៉ាកiPhone ស៊ិចភ្លើសពណ៌ទឹកមាសមកលក់ឱ្យខ្លួនក្នុងតម្លៃ២១0ដុល្លា ដោយទូរស័ព្ទនោះមានផ្ទាំងសាក និងកាសគ្រប់គ្រាន់ទើបនាងខ្ញុំហ៊ានទិញ ក្រោយពីទិញបានហើយខ្លួនក៏បានដាក់ក្នុងទូរសព្ទ័លក់ធម្មតា។ សូមបញ្ជាក់ ថាទូរស័ព្ទនេះខ្ញុំពុំបានដឹងថាពួកគាត់បានមកពីណាទេ។ ទើបមកដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៧និង៣0នាទី ក៏ឃើញមានសមត្ថកិច្ចនាំជនដែលលក់ទូរស័ព្ទឱ្យខ្លួននោះមកហាងខ្លួនហើយសមត្ថកិច្ចបានអញ្ជើញខ្លួនមកសួរ ទើបខ្ញុំថាទូរស័ព្ទនោះពាក់ពន្ធ័ នឹងអំពើឃាតកម្ម ហើយខ្លួនសូមប្រគល់ទូរស័ព្ទនេះជូនសមត្ថកិច្ចវិញដោយស្ម័គ្រចិត្តមិនតវ៉ាទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ......បានឆ្លើយថា៖ ចំពោះចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅសមត្ថកិច្ច កាលពី ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ គឺខ្លួនទទួលស្គាល់ដោយមិនមានការកែប្រែទេ។ ខ្លួននិងជនរងគ្រោះគឺធ្លាប់ទាក់ទងគ្នាជាសង្សាររយៈពេលប្រហែល០១ឆ្នាំហើយហើយ រីឯជនល្មើសវិញខ្លួនមិនដែលស្គាល់នោះទេ ហើយជនរងគ្រោះក៏មិនដែលប្រាប់ពីព័ត៌មានទាក់ទងនឹងជនល្មើសឱ្យខ្លួនដឹងដែរ។ ថ្ងៃដែលខ្លួនបានជួបនឹងជនរងគ្រោះចុងក្រោយបំផុតគឺនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង០៤ រសៀលជិតម៉ោង៥រសៀលគឺខ្លួនទៅយកមួកសុវត្ថិភាពនៅផ្ទះរបស់គាត់ជួលហើយ ក៏បែកគ្នាទៅ។ថ្ងៃដែលខ្លួនដឹងថាជនរងគ្រោះស្លាប់ គឺនៅថ្ងៃទី២៥ខែតុលាឆ្នាំ២០១៦ម៉ោងប្រហែល៥រសៀលតាមរយៈមិត្តភក្ត្រ័ស្រីរបស់ឈ្មោះ....ជាអ្នកទូរស័ព្ទប្រាប់ខ្លួន។ ខ្លួនបានដឹងតែប៉ុណ្ណឹងចំពោះរឿងអ្វីផ្សេងទៀតខ្លួនមិនបានដឹងទេ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលឃើញថា នៅចំណុចផ្ទះលេខ២០សេ ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ គឺពិតជាកើតមានអំពើឃាតកម្មគិតទុកជាមុនបង្កដោយជនជាប់ចោទឈ្មោះ.......មែនដែលអំពើនេះបានគិតទុកជាមុន អំពើនេះត្រូវបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ជនជាប់ចោទក៏បានសារភាពដែរថា ខ្លួនបាន ប្រើប្រាស់គ្រឿងញៀនផងដែរ ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ៣៩៨៣ អ.យ.ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ទុកជាបានការ និងសុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-លោក........ជាមេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ យោងតាមការពិភាក្សាដេញដោលឃើញថា កូនក្តីខ្លួនពុំមានទោសពីមុន មានកម្រិតវប្បធម៌ទាប និងជាជាងពិដាន ដោយ កូនក្តីខ្លួនមានការខឹងជនរងគ្រោះដោយកំហឹង ពុំមែនមានគម្រោងសម្លាប់ឡើយ គឺកូនក្តីខ្លួនខឹងភ្លាមក៏ស្ទុះសង្កត់ជនរងគ្រោះ និងច្របាច់ក ក៏បណ្តាលឱ្យជនរងគ្រោះស្លាប់ភ្លាមៗ គឺពុំមានគម្រោងពីមុនទេ។ពេលជនរងគ្រោះស្លាប់ហើយ កូនក្តី ខ្លួនក៏ដោះយកសម្ភារ ព្រោះសម្ភារទាំងនោះជារបស់ដែលកូនក្តីខ្លួនទិញឱ្យជនរងគ្រោះ ហើយកូនក្តីខ្លួនយកទៅគឺដោះដូរ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ដូចនេះខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តា ប្តូរបទចោទប្រកាន់ពីមាត្រា២០០ ទៅជាមាត្រា២២៤ វិញ គឺហិង្សាដោយមានមរណភាពជនរងគ្រោះ។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ......សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យពិចារណានិងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

-កាលពីថ្ងៃទី២៤ខែតុលាឆ្នាំ២០១៦ មានករណីឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនកើតឡើងនៅចំណុចបន្ទប់លេខ ២០សេ ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម ២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-ជនជាប់ចោទឈ្មោះ......ភេទប្រុសអាយុ៣៨ឆ្នាំ ជាតិខ្មែរ ជាទីតិជននិង ជាជនមានសមត្ថភាពអាចទទួលខុសត្រូវ ពីបទព្រហ្មទណ្ឌបាន។

-តាមការអះអាងរបស់ជនជាប់ចោទឈ្មោះ.......បានបញ្ជាក់ថា៖កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ខ្លួនបានទូរស័ព្ទណាត់ជាមួយឈ្មោះ.....ភេទស្រីអាយុ២២ឆ្នាំ ទៅជួបគ្នានៅម៉ោង ៤ឬ៥ល្ងាច នៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុន ខ្លួនក៏បានជួលបន្ទប់ផ្ទះសំណាក់លេខ២០សេ ដល់ម៉ោង៥និង៣០នាទីឈ្មោះ........បានមកដល់ បន្ទាប់មកពួកខ្លួនបានរួមភេទ

គ្នា ក្រោយពីរួមភេទគ្នារួច ម៉ោងប្រហែល៩និង៣០នាទីពួកខ្លួនបាននិយាយគ្នា ដោយខ្លួន ថាឱ្យគាត់ឈប់ធ្វើការជានារីខារ៉ាអូខេតែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបង្អួតខ្លួនថាគាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរស័ព្ទឆ្លើយឆ្លងនៅចំពោះមុខខ្លួន ពេលនោះខ្លួនខឹងពេកក៏បានសង្គ្រប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតច្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួចខ្លួនបានដោះខ្សែក ដោះខ្សែដៃ និងយកទូរស័ព្ទរបស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង ហើយនៅមុនពេលខ្លួនសម្លាប់ជនរងគ្រោះ ខ្លួនបានព្រមានថាឱ្យឈប់ទាក់ទងជាមួយប្រុសទៀត បើនៅតែធ្វើបែបនេះ ខ្លួននឹងសម្លាប់ចោល ដែលការសារភាពនេះតុលាការអាជឿបាន ព្រោះវាស៊ីសង្វាក់នឹងចម្លើយរបស់សាក្សីឈ្មោះ.......ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់ អូយេស ហើយកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៦ និង៤៥នាទីមានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល ៣២ឆ្នាំ ប្រើទូរស័ព្ទលេខ ០៩៦៨៣៧៦៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ៨ដុល្លា បន្ទប់លេខ២០សេ ជាន់ទី៣ ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឱ្យឡើងទៅបន្ទប់២០សេ រហូតមកដល់វេលាម៉ោងប្រហែល១៧និង០៥នាទី ភ្ញៀវស្រីម្នាក់មកដល់ ក៏សួររកបន្ទប់លេខ២០សេ ខ្លួនក៏ប្រាប់ឱ្យឡើងមកជាន់ទី៣ជាប់នឹងជណ្តើរឡើង។ លុះដល់វេលាម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោះ......ជាអ្នកសំអាតបន្ទប់ ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់២០សេ ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេកដណ្តប់ភួយស្លាប់នៅលើគ្រែមែន។

-អំពើដែលជនជាប់ចោទឈ្មោះ.....ដែលបានប្រើប្រាស់ថ្នាំញៀននៅមុនពេលសម្លាប់ជនរងគ្រោះ និងគិតថានឹងសម្លាប់ជនរងគ្រោះបើសិនជនរងគ្រោះមានប្រុសក្បត់ខ្លួន ហើយនៅថ្ងៃកើតហេតុ ជនជាប់ចោទក៏បានច្របាច់កជនរងគ្រោះ រហូតស្លាប់ និងដោះយកសម្ភារជនរងគ្រោះនោះ ត្រូវចាត់ជាអំពើឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-វត្ថុចាប់យករួមមានកៅស៊ូចងសក់ ពណ៌ខ្មៅចំនួន០៣ កែវជ័រចំនួន០១ និងស្បែកជើងផ្ទាត់ចំនួន០១គូ ម៉ាសមុខ កន្សែងពោះគោពណ៌សចំនួន០២ កន្សែង០១ត្រូវរហែកប្រឡាក់ឈាម អាវរ៉ូបមួយពណ៌សឆ្នូតពណ៌ខ្មៅ០១ អាវទ្រនាប់០១ ខោលីអូ០១ និងកាតទូរស័ព្ទរឹងចំនួន០២ សន្លឹក សំបកបាកាស់០១ M១៥០ ១ដប គោជល់០១ដប អាវដៃវែងឆ្នូត ក្រហមមួយគឺជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើស និងជាភស្តុតាងបញ្ជាក់ពីអំពើល្មើសរបស់ជនជាប់ចោទ គប្បីតុលាការ រឹបអូសតាមច្បាប់។ ចំណែកឯវត្ថុចាប់យករួមមានកាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌សចំនួន០១ ទូរស័ព្ទដៃ០១ គ្រឿងម៉ាកណូគា ពណ៌លឿងនិងឌីសចំនួន០១ កាបូបដៃចំនួន០១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានឈ្មោះ....និងវិក្ក័យបត្រទិញលក់មាសចំនួន០៣សន្លឹក គឺជាសម្ភាររបស់ជនរងគ្រោះនិងជាសម្ភារៈរបស់ជនជាប់ចោទ ហើយពុំមានពាក់ព័ន្ធនឹងអំពើល្មើសឡើយ ដូចនេះតុលាការគប្បីប្រគល់ឱ្យម្ចាស់ដើមវិញ។

-មានពិរុទ្ធភាពលើឈ្មោះ....ភេទប្រុសអាយុ៣៨ឆ្នាំជាតិខ្មែរ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រព្រឹត្តនៅចំណុចបន្ទប់លេខ២០សេ ជាន់ទី៣ផ្ទះសំណាក់យីហោ អូយេស ស្ថិតនៅផ្លូវ

លេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌនិងមាត្រា៤៥ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងឈ្មោះ......ពុំបានចូលមកតាំងខ្លួនជាដើមបណ្តឹង និងប្តឹងទាមទារសំណងជំងឺចិត្តឡើយ ដូចនេះតុលាការ គប្បីទុកសិទ្ធិជូនដើមបណ្តឹងទាមទារសំណងពេលក្រោយតាមច្បាប់ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ.....ភេទប្រុសអាយុ៣៨ឆ្នាំជាតិខ្មែរ ដាក់ពន្ធនាគារសរុបកំណត់ មួយជីវិត ពីបទៈឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់២០សេ ជាន់ទី៣ ផ្ទះសំណាក់ឃីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា៦២ និងាមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌគឺ៖

-កៅស៊ូចងសក់ពណ៌ខ្មៅចំនួន០៣ ពណ៌ខ្មៅចំនួន០៣ កែវជ័រចំនួន០១ និងស្បែកជើងផ្ទាត់ចំនួន០១គូ

-ម៉ាសមុខ កន្សែងពោះគោពណ៌សចំនួន០២ កន្សែង០១ត្រូវហែកប្រឡាក់ឈាម

-អាវរ៉ូបមួយពណ៌សឆ្នូតពណ៌ខ្មៅ០១ អាវទ្រនាប់០១ ខោលីអូ០១ និងកាតទូរស័ព្ទវីងចំនួន០២ សន្លឹក

-សំបកបាកាស់០១ M១៥០ ១ដប គោជល់០១ដប អាវដៃវែងនិងឆ្នូតក្រហមមួយ។

៣-វត្ថុចាប់យកត្រូវប្រគល់ឱ្យម្ចាស់ដើមវិញគឺ៖

-កាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌សចំនួន០១

-ទូរស័ព្ទដៃ០១ គ្រឿងម៉ាកណូគា ពណ៌លឿងនិងឪសចំនួន០១

-កាបូបដៃចំនួន០១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានឈ្មោះ....និងវិក្ក័យបត្រទិញលក់មាសចំនួន០៣សន្លឹក។

-សាលក្រមនេះជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី១៦-០៣-២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ......កំបាំងមុខ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ.......ប្រកាសជាសាធារណៈនៅថ្ងៃទី២៨-០៣-២០១៧ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។